**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**

**សភាព្រហ្មទណ្ឌ**

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៨៤

ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៩

**សាលដីកា**

លេខ ០១ "III"

ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០២០

ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម:

| | | |
|---|---|---|
| ១-ឯកឧត្តម | [redacted] | ជាប្រធាន |
| ២-លោក | [redacted] | ជាចៅក្រម |
| ៣-លោក | [redacted] | ជាចៅក្រមរបាយការណ៍ |
| ៤-លោក | [redacted] | ជាចៅក្រម |
| ៥-លោក | [redacted] | ជាចៅក្រម |

**ក្រឡាបញ្ជីសវនាការ**

កញ្ញា [redacted]

**តំណាងមហាអយ្យការ**

ឯកឧត្តម [redacted] ឋានៈជាអគ្គព្រះរាជអាជ្ញារង

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងសាទុក្ខលេខ ៤៨ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted]វណ្ណៈ ក្នុងការប្តឹងសាទុក្ខចំពោះសាលដីកាព្រហ្មទណ្ឌលេខ ១៤ ក្រIVរធ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលមាន៖

**បុគ្គលប្តឹងសាទុក្ខ** ៖ ជនជាប់ចោទឈ្មោះ [redacted]វណ្ណៈ ហៅ ទូច ភេទប្រុស អាយុ ២៥ ឆ្នាំ ជាតិខ្មែរ មុខរបរព្រូឡាន ទីកន្លែងកំណើតនៅភូមិរាំង ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។ ទីលំនៅបច្ចុប្បន្ន [redacted] ខេត្តកំពង់ស្ពឺ ។ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] "រ" កូនគ្មាន ។ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គឺធ្លាប់ជាប់ពន្ធនាគារពីបទហិង្សាដោយចេតនា មានស្ថានទម្ងន់ទោស ទោសជាប់ពន្ធនាគាររយៈពេល ០៤ ឆ្នាំ កាលពីឆ្នាំ២០១៣ ។



Scanned with CamScanner

-មានលោកមេធាវី [redacted] គុយុសៀក ជាអ្នកការពារ ។

ជាប់ចោទពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅរាជធានីភ្នំពេញ នៅក្នុងអំឡុងឆ្នាំ ២០១៧ តាមបទប្បញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

<u>អំពីអង្គហេតុ៖</u>

កាលពីអំឡុងឆ្នាំ២០១៧ ជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ ភេទប្រុស អាយុ ២៥ ឆ្នាំ បានទិញគ្រឿងញៀនពីឈ្មោះ ឌី ភេទប្រុស អាយុប្រហែល ៣០ ឆ្នាំ នៅម្តុំរង្វង់មូលចោមចៅ ដើម្បីយកមករំលែកលក់បន្តចំនួន ៤ លើក ៖ លើកទី១ នៅចុងខែឧសភា ឆ្នាំ២០១៧ ទិញទម្ងន់ ២ ជី តម្លៃ ២៤០ (ពីររយសែសិប) ដុល្លារអាមេរិក, លើកទី២ នៅអំឡុងពាក់កណ្តាលខែមិថុនា ឆ្នាំ២០១៧ ទិញចំនួនកន្លះជ្រុង តម្លៃ ៣០០ (បីរយ) ដុល្លារអាមេរិក, លើកទី៣ នៅអំឡុងចុងខែមិថុនា ឆ្នាំ២០១៧ ទិញគ្រឿងញៀនទម្ងន់ ៤ ជី តម្លៃ ៤៧០ (បួនរយចិតសិប) ដុល្លារអាមេរិក និង លើកទី៤ នៅក្នុងខែកក្កដា ឆ្នាំ២០១៧ ទិញទម្ងន់ ៦ ជី តម្លៃ ១០០០ (មួយពាន់) ដុល្លារអាមេរិក ។ ប៉ុន្តែមិនទាន់បានចែកចាយផង ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួន និងដកហូតគ្រឿងញៀន និងនាំទៅធ្វើការស៊ើបអង្កេតតែម្តង ។

-បានឃើញ សាលក្រមលេខ ៧៩៤ "ហ"ក្រ៥ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ផ្តន្ទាទោសលើឈ្មោះ [redacted] វណ្ណៈ ហៅ ទូច ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៨ (ប្រាំបី) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១០.០០០.០០០ (ដប់លាន) រៀល ។

ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅរាជធានីភ្នំពេញ នៅក្នុងអំឡុងឆ្នាំ២០១៧ បទល្មើសដែលមានចែងនិងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៥ ចំណុចទី៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២-វត្ថុចាប់យក

ក.សំណាកគ្រឿងញៀនប្រភេទម្សៅក្រាមឈ្មោះមេតំហ្វេតាមីន (ហៅក្រៅថា ម៉ាទឹកកក ឬ Ice ) ទម្ងន់ ៤៩,៨១ (សែសិបប្រាំបួន ក្បៀសប៉ែតសិបមួយ) ក្រាម នៅសល់ពីការដកហូតសំណាកធ្វើកោសល្យវិច័យ តាមកំណត់ហេតុបើកនិងបិទបញ្ចប់សំណាកសង្ស័យថាជាសារធាតុញៀន យកទៅធ្វើកោសល្យវិច័យ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ត្រូវរឹបអូសបំផ្លាញចោល ។

ខ.ជញ្ជីងថ្លឹងគ្រឿងញៀនចំនួន ០១ ត្រូវរឹបអូស ។

គ.ទូរស័ព្ទម៉ាក NOKIA ចុចពិល ពណ៌ខៀវ ០១ គ្រឿង ត្រូវប្រគល់ឱ្យម្ចាស់ដើមវិញ ។

សាលក្រមនេះ ជំនុំជម្រះនៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៧ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០១៧ ចំពោះមុខជនជាប់ចោទ។

បើកផ្លូវឱ្យប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ១៣ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ ថន វណ្ណៈ ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៧៩៤ "ហ"ក្រ៥ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

សាលាឧទ្ធរណ៍ភ្នំពេញបានសម្រេចតាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ ១៤ ក្រIVវន ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖



Scanned with CamScanner

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ១៣ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ ហៅ ទូច ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៧៩៤ "ហ" ក្រ៥ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

៣-សាលដីកានេះ ជំនុំជម្រះនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ ហៅ ទូច មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទ ។

-ទុកសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងសាទុក្ខលេខ ៤៨ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ ក្នុងការប្តឹងសាទុក្ខ បានប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ១៤ ក្រIVទន ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

**នាពេលសវនាការ**

-ចៅក្រមរបាយការណ៍បានអានរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូលធ្វើសេចក្តីសន្និដ្ឋានសុំថា ដូច្នេះ ដើម្បីផលប្រយោជន៍ច្បាប់ និងផលប្រយោជន៍យុត្តិធម៌ចំពោះភាគីនៅក្នុងសំណុំរឿងព្រហ្មទណ្ឌនេះ តំណាងមហាអយ្យការសន្និដ្ឋានសុំក្រុមប្រឹក្សាជំនុំជម្រះពិចារណានិងសម្រេចតាមគតិច្បាប់ដែលពាក់ព័ន្ធនឹងសំណុំរឿងព្រហ្មទណ្ឌនេះ ក្នុងអង្គហេតុ និងសំអាងហេតុដូចបានបញ្ជាក់ខាងលើ ដោយស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចៈ

១-ទទួលបណ្តឹងសាទុក្ខលេខ ៤៨ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១៤ក្រIVទន ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការដដែល ។

-លោកមេធាវី [redacted] គុជ្យសៀក បានធ្វើសេចក្តីសន្និដ្ឋានថា តាមបរិមាណភាពសុទ្ធនៃសារធាតុញៀនជាប្រភេទមេតំហ្វេតាមីន ដែលបានចាប់យកពីកូនក្តីខ្លួនមានចំនួនត្រឹមតែ ៤១,២២ ក្រាម ហើយការដែលតុលាការអង្គសេចក្តីប្រកាសទោសលើកូនក្តីខ្លួនដោយផ្អែកតាមបទប្បញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៥ ចំណុចទី៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀននោះ ជាការត្រឹមត្រូវហើយ ក៏ប៉ុន្តែចំណុចដែលកូនក្តីខ្លួនប្តឹងសាទុក្ខនោះ គឺចំណុចទណ្ឌកម្មដាក់ពន្ធនាគារកំណត់ ៨ (ប្រាំបី)ឆ្នាំ ជាការមិនត្រឹមត្រូវ មិនសមស្របនោះទេ ពីព្រោះថាតាមខ្លឹមសារនៃមាត្រា ៤០ កថាខណ្ឌទី៥ ចំណុចទី៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដាក់ពន្ធនាគារកំណត់ពី ៥ ឆ្នាំ ទៅ ១០ ឆ្នាំ ចំពោះបរិមាណភាពសុទ្ធនៃសារធាតុញៀនប្រភេទតំហ្វេតាមីន មានទម្ងន់ចាប់ពី ១៥ ក្រាម ទៅដល់ក្រោម ៨០ ក្រាម។ ដូច្នេះកូនក្តីខ្លួនពុំគប្បីត្រូវទទួលរងទណ្ឌកម្មរហូតដល់ទៅ ៨ ឆ្នាំនោះទេ។ ដូច្នេះឃើញថា ការផ្តន្ទាទោសលើកូនក្តីខ្លួនមានលក្ខណៈធ្ងន់ធ្ងរពេកហើយ ។



Scanned with CamScanner

សំណូមពរ៖ សូមឱ្យក្រុមប្រឹក្សាមេត្តាពិនិត្យ ពិចារណា បន្ធូរបន្ថយទោស ដល់កូនក្តីរបស់ខ្លួនផង។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សា វិនិច្ឆ័យ ត្រឹមត្រូវតាមច្បាប់ហើយ

**សំអាងហេតុ**

**តុលាការកំពូល**

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៤៨ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ បានធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមបទប្បញ្ញត្តិមាត្រា ៦៤ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងបទប្បញ្ញត្តិមាត្រា៤១៧ ,មាត្រា៤១៨ និងមាត្រា៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជម្រះបាន។

២-យល់ឃើញថា ជនជាប់ចោទអវត្តមាននាពេលសវនាការ ក៏ប៉ុន្តែជនជាប់ចោទបានដាក់សារណាការពារបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខជូនមកតុលាការកំពូលរួចហើយ ហើយមេធាវីការពារក្តីរបស់ជនជាប់ចោទមានវត្តមានដែរ ។ ដោយសវនាការតុលាការកំពូលនាពេលនេះ គឺជាសវនាការពិនិត្យតែលើបញ្ហាអង្គច្បាប់ ហើយអគ្គព្រះរាជអាជ្ញារងជាតំណាងមហាអយ្យការអមតុលាការកំពូល នឹងមេធាវីមិនជំទាស់នឹងការបន្តនីតិវិធីជំនុំជម្រះ ដូច្នេះតុលាការកំពូលអាចធ្វើសវនាការលើរឿងក្តីនេះបាន ។

៣-យល់ឃើញថា តាមសារណាបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩ និងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីឱ្យជនជាប់ចោទនាពេលសវនាការថា តាមបរិមាណភាពសុទ្ធនៃសារធាតុញៀនប្រភេទមេតំហ្វេតាមីនដែលបានចាប់យកពីកូនក្តីខ្លួនមានចំនួនត្រឹមតែ ៤១,២២ ក្រាម ហើយការដែលតុលាការអង្គសេចក្តីប្រកាសទោសលើកូនក្តីខ្លួនដោយផ្អែកតាមបទប្បញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៥ ចំណុចទី៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀននោះ ជាការត្រឹមត្រូវហើយ ក៏ប៉ុន្តែចំណុចដែលកូនក្តីខ្លួនប្តឹងសាទុក្ខនោះ គឺចំណុចទណ្ឌកម្មដាក់ពន្ធនាគារកំណត់ ៨ (ប្រាំបី) ឆ្នាំ ជាការមិនត្រឹមត្រូវ មិនសមស្របនោះទេ ពីព្រោះថា តាមខ្លឹមសារនៃមាត្រា ៤០ កថាខណ្ឌទី៥ ចំណុចទី៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនចែងថា "ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ពី ៥ ឆ្នាំ ទៅ ១០ ឆ្នាំ ចំពោះបរិមាណភាពសុទ្ធនៃសារធាតុញៀនប្រភេទអំហ្វេតាមីន មេតំហ្វេតាមីន ឬអ៊ិចស្តាស៊ី មានទម្ងន់ចាប់ពី ១៥ ក្រាម ទៅដល់ក្រោម ៨០ ក្រាម ។ ដូច្នេះ កូនក្តីខ្លួនពុំគប្បីត្រូវទទួលរងទណ្ឌកម្មរហូតដល់ទៅ ៨ ឆ្នាំ ដូចនេះទេ ។ សុំឱ្យក្រុមប្រឹក្សាជំនុំជម្រះពិចារណាសម្រេចបន្ធូរបន្ថយទោសមកនៅក្នុងកម្រិតមួយដែលសមស្របទៅនឹងទម្ងន់នៃសារធាតុសុទ្ធដែលកូនក្តីរបស់ខ្លួនបានប្រព្រឹត្តនោះ តុលាការកំពូលពិចារណាឃើញថា បណ្តឹងសាទុក្ខនេះមានមូលហេតុនៃបណ្តឹងសាទុក្ខសមស្របតាមបទប្បញ្ញត្តិមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលតុលាការអង្គសេចក្តីបានប្រកាស



Scanned with CamScanner

ទោសមិនសមស្របតាមកម្រិតសមាមាត្រធៀបជាមួយនឹងបរិមាណភាពសុទ្ធនៃសារធាតុញៀនដែលជនជាប់ចោទបានជួញដូរ ហើយដែលត្រូវបានកងកម្លាំងមានសមត្ថកិច្ចបានចាប់យក ។

៤-យល់ឃើញថា តុលាការអង្គសេចក្តីបានប្រកាសទោសចំពោះជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ ក្នុងករណីនេះមានលក្ខណៈធ្ងន់ មិនសមាមាត្រជាមួយនឹងកម្រិតបរិមាណភាពសុទ្ធនៃសារធាតុញៀនដែលជនជាប់-ចោទបានជួញដូរនោះឡើយ ។

៥-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ១៤ ក្រIVរន ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញដែលបានសម្រេចសេចក្តីមកនេះ ត្រឹមត្រូវតាមច្បាប់ខ្លះ ខុសខ្លះ ។

**ហេតុដូច្នេះ**

**តុលាការសម្រេចសេចក្តី**

១-ឧទ្ធរណ៍ផ្នែកខ្លះនៃបណ្តឹងសាទុក្ខលេខ ៤៨ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ១៤ ក្រIV នរ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ទុកជាបានការដដែល។ លើកលែងតែចំណុចសម្រេចអំពីកម្រិតទោសដែលបានសម្រេចនិងប្រកាសចំពោះជនជាប់ចោទ។

៣-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ ៨៤ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៩ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីជំនុំជម្រះជាថ្មីលើចំណុចការសម្រេចនិងប្រកាសអំពីកម្រិតទោសលើជនជាប់ចោទ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃសុក្រ ទី០៣ ខែមករា ឆ្នាំ២០២០ និងប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃសុក្រ ទី១០ ខែមករា ឆ្នាំ២០២០ ។



Scanned with CamScanner